ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

លេខៈ ៥៧៦/...សភភព.កស /២០២១

## សេចក្តីជូនដំណឹង

## ស្តីអំពីការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់បណ្ឌិតផ្នែករូបវិទ្យា ជំនាន់ទី១ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

**យោងៈ** ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ៤៨៧ អយក.ប្រ.ក. ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ស្តីអំពីការបើកវគ្គបណ្តុះបណ្តាលថ្នាក់បណ្ឌិតផ្នែករូបវិទ្យា។

ដោយមានកិច្ចសហការរវាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាមួយសាកលវិទ្យាល័យសកាំងរបស់សាធារណៈរដ្ឋកូរ៉េ តាមរយៈគម្រោងភាពជាដៃគូរវាងសភភព និងសាកលវិទ្យាល័យសកាំង (Sogang University) នៃគម្រោងកែលម្អគុណភាពអប់រំឧត្តមសិក្សា និងជាមួយ Swedish International Development Cooperation Agency របស់ប្រទេសស៊ុយអែតតាមរយៈ Sweden-RUPP Bilateral Program សាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញនឹងរៀបចំការប្រឡងជ្រើសរើសនិស្សិតឲ្យចូលសិក្សាថ្នាក់បណ្ឌិតផ្នែករូបវិទ្យា ជំនាន់ទី១ សម្រាប់ឆ្នាំសិក្សា ២០២១-២០២២។ កម្មវិធីនេះត្រូវរៀនជាភាសាខ្មែរ និងភាសាអង់គ្លេស (ថ្នាក់ពេញម៉ោង)។ ទទួលពាក្យចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃចន្ទ១១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ម៉ោង១៦:០០។

**លក្ខខណ្ឌជ្រើសរើសៈ**
- បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែករូបវិទ្យា
- មានសមត្ថភាពភាសាអង់គ្លេស អាចប្រើការបានសម្រាប់ការសិក្សា និងស្រាវជ្រាវថ្នាក់បណ្ឌិត

**សំណុំលិខិតៈ**
- ពាក្យសុំចុះឈ្មោះប្រឡង ០១ច្បាប់
- សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែករូបវិទ្យា ០១ច្បាប់
- តារាងពិន្ទុថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់រូបវិទ្យា ០១ច្បាប់
- សំណើស្រាវជ្រាវសង្ខេប (៣-៥ ទំព័រ) ពន្យល់អំពីគំនិតស្រាវជ្រាវដែលខ្លួនមានបំណងធ្វើ
- ប្រវត្តិរូប (CV សរសេរតាមទម្រង់ផ្ទាល់ខ្លួន) ដោយបង្ហាញអំពីការបោះពុម្ពកន្លងមកបើមាន
- រូបថតថ្មី (ផ្ទៃពណ៌ខៀវ) ទំហំ ៤ x ៦ ចំពីមុខឥតពាក់វ៉ែនតាចំនួន ០៣សន្លឹក និងទំហំ ៣ x ៤ ចំនួន ០២សន្លឹក

**សម័យប្រឡងៈ** ថ្ងៃចន្ទ០៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១

**វិញ្ញាសាប្រឡងៈ**
- មេកានិកទ្រឹស្តី (៨:០០ - ១០:០០)
- រូបវិទ្យាកង់ទិច (១០:១០ - ១២:១០)

**ថ្លៃសិក្សាៈ**
- បេក្ខជនត្រូវបង់សិទ្ធប្រឡងចំនួន ៣០.០០ ដុល្លារ
- និស្សិតត្រូវបង់ថ្លៃសិក្សា ៣,០០០.០០ ដុល្លារក្នុង១ឆ្នាំ (ឬមួយពាន់ប្រាំរយដុល្លារអាមេរិកក្នុង១ឆមាស)

**បញ្ជាក់ៈ**
- និស្សិតនឹងត្រូវទទួលការសម្ភាសបន្ថែមជាភាសាអង់គ្លេស ដើម្បីធ្វើការវាយតម្លៃបន្ថែមលើកម្រិតភាសា កម្រិតជំនាញរួមនិងបុគ្គលិកលក្ខណៈនិស្សិត។

**អាសយដ្ឋានទាក់ទងៈ** ព័ត៌មានបន្ថែម សូមទាក់ទងសាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ បន្ទប់ ៥០៣ ជាន់ទី៥ អគារស្វែម (សភភព) ឬតាមរយៈទូរស័ព្ទលេខ៖ ០៨៥-២៨៩-៧៩១/០៦១-៣០២-០១៧/០១៥-៩៦៦-២៣៤

ថ្ងៃ......................ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី..........ខែកញ្ញា ឆ្នាំ២០២១

**ជ. សាកលវិទ្យាធិការ**

**សាកលវិទ្យាធិការរង**

ប៉ាល់ ដែស